ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# ទស្សនវិស័យ មុខរបរ និងការងារ

## តម្រូវការជំនាញ និងការងារសម្រាប់យុវជន



លេខ៥ ឆមាសទី១ ឆ្នាំ២០២៦

សម្រាប់ការដាក់ឯកសារយោង៖ អ៊ុំ ច័ន្ទមនោ, អ៊ុំ សូម៉ារ៉ា , គី សេរីវ៉ុធ, ប៊ុន បូពិត, ទ្រី សុផល, ថា ចាន់ថន។
ទស្សនវិស័យមុខរបរ និងការងារ៖ តម្រូវការជំនាញ និងការងារសម្រាប់យុវជន ឆមាសទី១ ឆ្នាំ២០២៦។
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

# អារម្ភកថា

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងនាមជាសេនាធិការដ៏សំខាន់របស់រាជរដ្ឋាភិបាលកម្ពុជា តែងតែប្រកាន់ខ្ជាប់នូវបេសកកម្មជាយុទ្ធសាស្ត្រក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ តាមរយៈការអភិវឌ្ឍមូលធនមនុស្ស និងការធ្វើទំនើបកម្មទីផ្សារការងារឱ្យមានភាពរស់រវើក ផលិតភាពខ្ពស់ និងធន់នឹងការប្រែប្រួលសកល។ ក្នុងបរិបទដែលពិភពលោកកំពុងឈានចូលដល់របត់ថ្មីនៃបដិវត្តន៍បច្ចេកវិទ្យា និងការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច ការដាក់ចេញនូវគោលនយោបាយទីផ្សារការងារសកម្ម គឺជាផែនទីបង្ហាញផ្លូវចម្បងក្នុងការធ្វើទំនើបកម្មប្រព័ន្ធទីផ្សារការងារកម្ពុជា ពង្រឹងយន្តការគាំពារសង្គម និងបង្កើនសមត្ថភាពប្រកួតប្រជែងជាតិនៅលើឆាកអន្តរជាតិ។ ការធ្វើបច្ចុប្បន្នភាពព័ត៌មានទីផ្សារការងារឱ្យបានទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយ គឺជាសសរស្តម្ភមិនអាចខ្វះបានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ ដើម្បីបង្កើត រក្សា និងបង្កើនឱកាសការងារប្រកបដោយគុណភាព ជាពិសេសសម្រាប់យុវជន និងកម្មករនិយោជិតទាំងក្នុង និងក្រៅប្រព័ន្ធ សំដៅសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

ចាប់តាំងពីដើមឆ្នាំ២០២៤ មក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំ និងបោះពុម្ពផ្សាយឯកសារ «ទស្សនវិស័យមុខរបរ និងការងារ» ចំនួន ៤លេខ រួចមកហើយ។ សម្រាប់ ឆមាសទី១ ឆ្នាំ២០២៦ នេះ ក្រសួងបានបន្តរៀបចំ និងបោះពុម្ពផ្សាយឯកសារនេះ «លេខ៥» ឡើងយ៉ាងសម្រិតសម្រាំងដើម្បីក្លាយជាត្រីវិស័យដ៏ច្បាស់លាស់សម្រាប់សិស្ស-និស្សិត អ្នកស្វែងរកការងារ និងនិយោជក តាមរយៈការវិភាគស៊ីជម្រៅលើនិន្នាការមុខរបរដែលមានសក្តានុពល និងតម្រូវការជំនាញអាទិភាពក្នុងវិស័យគន្លឹះ។ ខ្លឹមសារសំខាន់នៃការបោះពុម្ពផ្សាយនេះ ផ្តោតជាអាទិភាពលើការកំណត់កម្រិតគុណវុឌ្ឍិ និងជណ្តើរអាជីព ដើម្បីតម្រង់ទិសយុវជនក្នុងការជ្រើសរើសជំនាញសិក្សា ឬការបណ្តុះបណ្តាលបច្ចេកទេសឱ្យចំគោលដៅ និងឆ្លើយតបផ្ទាល់ទៅនឹងតម្រូវការជាក់ស្តែងនៃទីផ្សារការងារកម្ពុជា។ បន្ថែមលើនេះ ការបញ្ចូលព័ត៌មានអំពីតម្រូវការជំនាញឌីជីថល និងជំនាញទន់ នឹងក្លាយជាឧបករណ៍ដ៏មានសារៈសំខាន់សម្រាប់កម្មករនិយោជិតក្នុងការកសាងសមត្ថភាពបន្ថែម ដើម្បីធានាបាននូវស្ថិរភាពអាជីព និងភាពប្រកួតប្រជែងក្នុងយុគសម័យនៃការប្រែប្រួលបច្ចេកវិទ្យាយ៉ាងឆាប់រហ័ស។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ឯកសារមគ្គុទ្ទេសក៍នេះនឹងក្លាយជាប្រភពព័ត៌មានដ៏មានតម្លៃសម្រាប់គ្រប់ភាគីពាក់ព័ន្ធ ក្នុងការចូលរួមចំណែកអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជាឱ្យកាន់តែរឹងមាំ និងមានបរិយាបន្ន។ ក្រសួងនឹងបន្តខិតខំប្រឹងប្រែងឥតឈប់ឈរក្នុងការធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានទីផ្សារការងារ ដើម្បីធានាថាពលរដ្ឋកម្ពុជាគ្រប់រូបមានឱកាសទទួលបានការងារធ្វើសមរម្យ មានផលិតភាពខ្ពស់ និងសម្រេចបាននូវជោគជ័យក្នុងអាជីពការងារប្រកបដោយចីរភាព។

ថ្ងៃសុក្រ ១២ កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៦

**រដ្ឋមន្ត្រី**

**ហេង ស៊ួរ**

## មាតិកា

ផ្នែកទី១ សេដ្ឋកិច្ច និងទីផ្សារការងារ ឆ្នាំ ២០២៥ និង ២០២៦
ផ្នែកទី២ ជំនាញដែលមានតម្រូវការនាពេលអនាគត
ផ្នែកទី៣ មុខរបរ និងការងារតាមអនុវិស័យសំខាន់ៗ
ផ្នែកទី៤ ដំណើរអាជីព និងជំនាញសម្រាប់មុខរបរដែលមានតម្រូវការខ្ពស់សម្រាប់យុវជន
ផ្នែកទី៥ ការចាប់យកឱកាសបណ្ដុះបណ្ដាល ប្រឹក្សាយោបល់ការងារ និងថែទាំសុខភាព

## ផ្នែកទី១៖ សេដ្ឋកិច្ច និងទីផ្សារការងារឆ្នាំ ២០២៥ និង ២០២៦

សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២៥ មានអត្រាកំណើនប្រមាណ ៥,២% នៅចំពោះមុខភាពមិនច្បាស់លាស់នៃភូមិសាស្ត្រនយោបាយ ភាពយឺតយ៉ាវនៃការពង្រីកពាណិជ្ជកម្ម វិធានការពន្ធគយរបស់សហរដ្ឋអាម៉េរិក ការរិតត្បិតលក្ខខណ្ឌហិរញ្ញវត្ថុ និងការវិលត្រឡប់យ៉ាងគំហុកនៃជនទេសន្តរប្រវេសន៍។ ទោះជាយ៉ាងនេះក្ដី ទីផ្សារការងារកម្ពុជានៅតែបង្ហាញភាពវិជ្ជមាន ដោយសម្រេចបានការបង្កើតការងារថ្មីប្រមាណ ៨០ ម៉ឺននាក់ ធ្វើឱ្យចំនួនអ្នកមានការងារធ្វើសរុបកើនឡើងដល់ ១០,៧ លាននាក់ ដែលក្នុងនោះរួមមាន៖ វិស័យសេវាកម្ម ៤,៩ លាននាក់, វិស័យឧស្សាហកម្ម ៣,០ លាននាក់ និងវិស័យកសិកម្ម ២,៨ លាននាក់។

រូបភាពទី១៖ ចំនួនអ្នកមានការងារធ្វើ និងកំណើនការងារតាមវិស័យ (ឆ្នាំ ២០២៤ - ២០២៥)




### សម្គាល់បច្ចេកទេសសម្រាប់ ការព្យាករចំនួនការងារ

- កំណើនចំនួនការងារ ត្រូវបានព្យាករផ្អែកលើសូចនាករសំខាន់ពីរគឺ៖ (១) កំណើនតាមវិស័យដែលផ្ដល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង (២) ការគណនាមេគុណការងារតាមវិស័យ (Employment Coefficient = Workers/Output)។ ការគណនានេះប្រើប្រាស់វិធីសាស្ត្រ Auto-Regressive Integrated Moving Average (ARIMA)[១] និង Compound Annual Growth Rate (CAGR)[២] ដោយយោងតាមទិន្នន័យអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ឆ្នាំ ២០០០-២០២៣ និងទិន្នន័យបឋមនៃអង្កេតកម្លាំងពលកម្មឆ្នាំ ២០២៥។

១) Ky, S. (2023). Labor demand forecasting: The case of Cambodia. *Bulletin of Applied Economics*, *10*(2), 89–105.

២) Vinitha, Y., Chanikya, G., Suryanshu, & Maiti, S. (2023). Does growth of gross state domestic product can manage unemployment in India? A state-level analysis. *International Journal for Multidisciplinary Research*, *5*(5), 1–14.

**រូបភាពទី២៖ បម្រែបម្រួលចំនួនសហគ្រាស ក្រុមហ៊ុន រោងចក្រក្នុងប្រព័ន្ធ និងកម្មករនិយោជិត ឆ្នាំ ២០២៤ - ២០២៥**




*ប្រភព៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ*

ខណៈកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២៥ នៅតែមានសន្ទុះវិជ្ជមាន ចំនួនសហគ្រាស ក្រុមហ៊ុន និងរោងចក្រក្នុងប្រព័ន្ធ បានកើនឡើងសរុបចំនួន ១ ៨៥១ សហគ្រាស ធៀបនឹងឆ្នាំ ២០២៤ ដោយក្នុងនោះ សហគ្រាសក្នុងអនុវិស័យកាត់ដេរបានកើនឡើងចំនួន ៣០១ សហគ្រាស ខណៈអនុវិស័យក្រៅពីកាត់ដេរបានកើនរហូតដល់ ១ ៥៥០ សហគ្រាស។ កំណើននេះ គឺជាសញ្ញាណវិជ្ជមានដែលឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីវឌ្ឍនភាពនៃពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច ព្រមទាំងការបង្កើនជំនឿទុកចិត្តលើបរិយាកាសធុរកិច្ច និងការវិនិយោគនៅកម្ពុជា។

ទន្ទឹមនឹងនេះ ចំនួនកម្លាំងពលកម្មក្នុងប្រព័ន្ធក្នុងឆ្នាំ ២០២៥ បានបង្ហាញនូវកំណើនគួរឱ្យកត់សម្គាល់ ពោលគឺកើនឡើងចំនួន ៤០១ ៤៧៩ នាក់ ឬស្មើនឹង ២២% ធៀបនឹងឆ្នាំ ២០២៤។ ក្នុងនោះ វិស័យកាត់ដេរនៅតែជាកម្លាំងចលករចម្បងក្នុងការបង្កើតការងារ ដោយបានរួមចំណែកប្រមាណ ៥២% នៃកំណើនការងារសរុប (ស្មើនឹង ២១០ ០៤៦ នាក់) ដោយចំនួនកម្មករ និយោជិតក្នុងវិស័យនេះឱ្យកើនដល់ ១ ១៣៤ ០៩១ នាក់។ ដោយឡែក វិស័យក្រៅពីកាត់ដេរក៏បានបង្ហាញពីភាពរឹងមាំ និងសក្តានុពលខ្ពស់ជាមួយនឹងកំណើនចំនួន ១៩១ ៤៣៣ នាក់ ដែលនាំឱ្យចំនួនកម្មករនិយោជិតសរុបក្នុងវិស័យនេះកើនឡើងដល់ ១ ០៨៣ ៤៣៤ នាក់។

សន្ទុះកំណើនដ៏រឹងមាំទាំងក្នុង និងក្រៅវិស័យកាត់ដេរ មិនត្រឹមតែសបញ្ជាក់ពីភាពប្រសើរឡើងនៃបរិយាកាសធុរកិច្ចប៉ុណ្ណោះទេ ប៉ុន្តែបានឆ្លុះបញ្ចាំងពីការកើនឡើងនៃកម្រិតអនុលោមភាពរបស់ម្ចាស់សហគ្រាស និងការយល់ដឹងកាន់តែស៊ីជម្រៅរបស់កម្មករនិយោជិតអំពីសារៈសំខាន់នៃការឈានចូលក្នុងប្រព័ន្ធ។ ការណ៍នេះអនុញ្ញាតឱ្យកម្លាំងពលកម្មអាចទទួលបានការគាំពារសង្គមតាមរយៈក្របខណ្ឌច្បាប់ និងអត្ថប្រយោជន៍កាន់តែទូលំទូលាយ ដែលជាមូលដ្ឋានគ្រឹះក្នុងការបង្កើនផលិតភាព និងសន្តិសុខប្រាក់ចំណូលក្នុងរយៈពេលវែង។

ដោយឡែកសម្រាប់ឆ្នាំ ២០២៦ នេះ ទស្សនវិស័យសកល និងសេដ្ឋកិច្ចពិភពលោក ត្រូវបានព្យាករថានឹងសម្រេចបានអត្រាកំណើនជាមធ្យមប្រមាណ ៣,៣% ខណៈតម្រូវការសកលស្ថិតក្នុងភាពប្រុងប្រយ័ត្នខ្ពស់។ ស្ថានភាពនេះបណ្តាលមកពីការបន្តនៃភាពមិនច្បាស់លាស់ផ្នែកភូមិសាស្ត្រនយោបាយ ភាពយឺតយ៉ាវនៃពាណិជ្ជកម្មអន្តរជាតិ និងការរឹតត្បិតលក្ខខណ្ឌហិរញ្ញវត្ថុ។ ការថមថយនៃសន្ទុះសេដ្ឋកិច្ចសកលនេះ អាចបង្កជាផលប៉ះពាល់អវិជ្ជមានដោយផ្ទាល់ដល់តម្រូវការកម្លាំងពលកម្ម ជាពិសេសក្នុងបណ្តាប្រទេសដែលមានសេដ្ឋកិច្ចផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងខ្សែច្រវាក់តម្លៃសកល (Global Value Chains)។

ក្នុងបរិបទនៃសកលភាវូបនីយកម្ម និងការផ្លាស់ប្តូររចនាសម្ព័ន្ធប្រជាសាស្ត្រ ជំនាញវិភាគ និងការដោះស្រាយបញ្ហាស្មុគស្មាញនៅតែជាគ្រឹះដ៏សំខាន់ ប៉ុន្តែសមត្ថភាពបត់បែន (Adaptability) បានក្លាយជាតម្រូវការចាំបាច់មិនអាចខ្វះបាន។ ការផ្លាស់ប្តូររចនាសម្ព័ន្ធការងារកំពុងកើតឡើងយ៉ាងឆាប់រហ័សឆ្ពោះទៅរកសេដ្ឋកិច្ចបៃតង បច្ចេកវិទ្យាឌីជីថល និងទិន្នន័យ ដែលក្នុងនោះការងារពាក់ព័ន្ធនឹងថាមពលកកើតឡើងវិញ និងការវិភាគទិន្នន័យ (Data Analytics) ត្រូវបានរំពឹងថានឹងមានកំណើនខ្ពស់។ និន្នាការនេះតម្រូវឱ្យមានការរៀបចំក្របខណ្ឌគុណវុឌ្ឍិ និងជណ្តើរអាជីពឱ្យបានច្បាស់លាស់ ដើម្បីតម្រង់ទិសយុវជនឱ្យចាប់យកជំនាញដែលឆ្លើយតបនឹងតម្រូវការទីផ្សារការងារនាពេលអនាគត។

សម្រាប់កម្ពុជា ទោះបីជាសក្តានុពលតំបន់ និងសកលផ្តល់កាលានុវត្តភាពថ្មីៗក៏ដោយ ប៉ុន្តែការត្រៀមខ្លួនត្រូវធ្វើឡើងប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់។ កំណើនការងារត្រូវបានរំពឹងថានឹងផ្តោតលើវិស័យសេវាកម្មក្នុងស្រុក និងការផលិតដែលប្រើប្រាស់កម្លាំងពលកម្មជំនាញ ជាជាងការពង្រីកវិសាលភាពក្នុងទ្រង់ទ្រាយធំលើគ្រប់វិស័យ។ ដើម្បីឆ្លើយតបនឹងបដិវត្តន៍បច្ចេកវិទ្យា និងការប្រែប្រួលនៃបរិបទសកល រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវវិធានការគោលនយោបាយយុទ្ធសាស្ត្រ ដើម្បីធ្វើទំនើបកម្មប្រព័ន្ធទីផ្សារការងារ តាមរយៈការលើកកម្ពស់ការអភិវឌ្ឍមូលធនមនុស្ស និងការបង្កើនសមត្ថភាពប្រកួតប្រជែងជាតិឱ្យកាន់តែរឹងមាំ និងធន់ទៅនឹងការវិបត្តិនានា។

## ផ្នែកទី២៖ ជំនាញដែលមានតម្រូវការនាពេលអនាគត

ផ្នែកនេះនឹងពិនិត្យទៅលើនិន្នាការនៃជំនាញ និងសក្តានុពលមុខរបរសម្រាប់ទីផ្សារការងារសម្រាប់ឆ្នាំ២០២៦ ដោយផ្អែកទៅលើការព្យាករនិងវិភាគទៅលើតម្រូវការការងារ ដែលមានក្នុងអនុវិស័យទាំង ១៤។

រូបភាពទី៣៖ តារាងម៉ាទ្រីសមុខជំនាញដែលត្រូវនឹងមុខរបរកំពុងមានតម្រូវការសម្រាប់ឆ្នាំ ២០២៦




***សម្គាល់៖*** *មុខជំនាញទាំង ៦០ នេះ ត្រូវបានវិភាគ និងព្យាករណ៍ចេញពីមុខរបរចំនួន ៨០ ដែលកំពុងមានតម្រូវការក្នុងទីផ្សារការងារ និងបានកំណត់ដោយផ្អែកតាមចំណាត់ថ្នាក់ស្តង់ដារអន្តរជាតិនៃការអប់រំ (ISCED-F 2013)។*

***ប្រភព៖*** *ការប៉ាន់ស្មានរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ផ្អែកលើទិន្នន័យអង្កេតទស្សនវិស័យការងារកម្ពុជា ឆមាសទី១ ឆ្នាំ២០២៦ និងឯកសារយោងចំនួន ៤៖ The Future of Jobs Report 2025 (World Economic Forum), Workforce 2030: Skills for thriving in the green and digital transitions (ILO, 2025), Employment and Social Trends (ILO, 2026) និង Quality Jobs and the Future of Work in Asia and the Pacific (ADB, 2024)។*

*__កំណត់ចំណាំ៖__*

- ***ការ៉េទី១៖*** *ជាក្រុមជំនាញកម្រិតខ្ពស់ ដែលឆ្លើយតបចំគោលដៅទៅនឹងមុខរបរដែលមានតម្រូវការខ្លាំងក្នុងទីផ្សារការងារនាពេលបច្ចុប្បន្ន។*
- ***ការ៉េទី២៖*** *ជាក្រុមជំនាញខ្ពស់ ដែលត្រូវនឹងមុខរបរដែលកំពុងមានតម្រូវការទាប ឬមធ្យម ក្នុងទីផ្សារការងារបច្ចុប្បន្ន។*
- ***ការ៉េទី៣៖*** *ជាក្រុមដែលមានជំនាញបច្ចេកទេសកម្រិតទាប ឬមធ្យម ប៉ុន្តែត្រូវនឹងមុខរបរដែលមានតម្រូវការកម្លាំងពលកម្មខ្ពស់ក្នុងទីផ្សារការងារនាពេលបច្ចុប្បន្ន។*
- ***ការ៉េទី៤៖*** *ជាក្រុមដែលមានកម្រិតជំនាញទាប ដែលត្រូវនឹងមុខរបរកំពុងមានតម្រូវការទាបក្នុងទីផ្សារការងារនាពេលបច្ចុប្បន្ន។*

រូបភាពទី១ ជាម៉ាទ្រីសដែលត្រូវបានបែងចែកជា ៤ កាដ្រង់ ដើម្បីផ្តល់ជាព័ត៌មានសំខាន់ដល់សិស្សានុសិស្ស និងអ្នកស្វែងរកការងារធ្វើ ក្នុងការកំណត់ទិសដៅអភិវឌ្ឍសមត្ថភាព និងជំនាញឱ្យស្របតាមតម្រូវការទីផ្សារការងារនាពេលអនាគត។ ជំនាញដែលមានសក្តានុពលខ្ពស់ ស្ថិតនៅកាដ្រង់ទី១ រួមមាន វិទ្យាសាស្ត្រទិន្នន័យ និងកម្មវិធី Gen AI, បច្ចេកវិទ្យាឌីជីថល, វិស្វកម្មរថយន្ត នាវា និងយន្តហោះ, សេដ្ឋកិច្ច, និងអេឡិចត្រូនិក និងស្វ័យប្រវត្តិកម្ម។ ផ្ទុយទៅវិញ ជំនាញដែលមានសក្តានុពលទាប ស្ថិតនៅកាដ្រង់ទី៤ ដែលភាគច្រើនជាជំនាញបច្ចេកទេសបែបប្រពៃណី ឬជំនាញដែលមានកម្រិតឯកទេសទាប ដែលអាចប្រឈមនឹងការថយចុះតម្រូវការ ឬការជំនួសដោយបច្ចេកវិទ្យា។ ដូច្នេះ ការជ្រើសរើសសិក្សាលើជំនាញដែលស្ថិតក្នុងកាដ្រង់ទី១ មិនត្រឹមតែជានាំនូវឱកាសការងារខ្ពស់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់នូវស្ថិរភាពការងារក្នុងយុគសម័យសេដ្ឋកិច្ចឌីជីថលទៀតផង។

## ផ្នែកទី៣៖ មុខរបរ និងការងារតាមអនុវិស័យសំខាន់ៗ

ការព្យាករសម្រាប់ឆ្នាំ២០២៦ បង្ហាញថា សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងមានអត្រាកំណើនក្នុងរង្វង់ ៥,០% ទោះបីជាមានការប្រឈមនឹងភាពមិនច្បាស់លាស់នៃភូមិសាស្ត្រនយោបាយសកល និងលក្ខខណ្ឌហិរញ្ញវត្ថុតឹងរ៉ឹងយ៉ាងណាក្តី (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ២០២៥)។ ទីផ្សារការងារនៅកម្ពុជានៅតែបង្ហាញសញ្ញាវិជ្ជមាន និងភាពធន់ ដោយមានអត្រាកំណើនការងារសរុបចំនួន ៤,២% ដែលស្មើនឹងការបង្កើតឱកាសការងារថ្មីចំនួន ៤៤៥ ០០០កន្លែង និងនាំឱ្យចំនួនអ្នកមានការងារធ្វើសរុបកើនឡើងដល់ ១១,២ លាននាក់សម្រាប់ឆ្នាំ ២០២៦។

រូបភាពទី៤៖ កំណើនការងារតាមវិស័យ (ឆ្នាំ២០២៥ - ២០២៦)




*ប្រភព៖ ការព្យាកររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដោយផ្អែកលើទិន្នន័យអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ២០០០-២០២៣ និងទិន្នន័យម៉ាក្រូរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

ក្នុងឆ្នាំ២០២៦ វិស័យឧស្សាហកម្មនៅតែបន្តដើរតួជាក្បាលម៉ាស៊ីនសេដ្ឋកិច្ចដ៏សំខាន់ ដោយរំពឹងថានឹងបង្កើតការងារថ្មីបានរហូតដល់ ២៨៥ ០០០ កន្លែង ដោយកំណើននេះទទួលបានការគាំទ្រពីការងើបឡើងវិញនៃ វិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប (GFT) និងការរីកចម្រើនយ៉ាងរហ័សនៃវិស័យផលិត និងដំឡើងយានយន្ត។

## រូបភាពទី៥៖ ទំហំនៃចំនួនកំណើនការងារតាមអនុវិស័យចម្បងៗ និងតាមកម្រិតជំនាញ នៅឆ្នាំ២០២៦




*ប្រភព៖ ការព្យាករបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយផ្អែកលើអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ២០០០-២០២៣*

*សម្គាល់៖ - ISCO: International Standard Classification of Occupations, CQF: Cambodia Qualifications Framework*

*- ទំនាក់ទំនងរវាងក្រុមមុខរបរធំៗ ISCO-08 និងកម្រិតជំនាញ - ISCO 1 ស្មើនឹងកម្រិតជំនាញ 3 និង 4, ISCO 2 ស្មើនឹងកម្រិតជំនាញ 4, ISCO 3 ស្មើនឹងកម្រិតជំនាញ 3, ISCO 4 5 6 7 និង8 ស្មើនឹងកម្រិតជំនាញ 2, ISCO 9 ស្មើនឹងកម្រិតជំនាញ 1។*

***តម្រូវការកម្រិតគុណវុឌ្ឍិ (CQF)៖***

- *អ្នកគ្រប់គ្រង វិស្វករ និងអ្នកមានជំនាញវិជ្ជាជីវៈ៖ បរិញ្ញាបត្រឡើងទៅ*
- *អ្នកបច្ចេកទេស៖ សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស*
- *ស្មៀន និងអ្នកធ្វើការផ្នែកសេវាកម្ម និងលក់៖ សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស*
- *កម្មករជំនាញជាន់ខ្ពស់ និងការីម៉ាស៊ីនរោងចក្រ និងបង្គុំដំឡើង៖ សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ*
- *កម្មករជំនាញ អ្នកប្រកបមុខរបរតូចតាចៗ និងអ្នកធ្វើការផ្នែកកសិកម្ម ព្រៃឈើ និងនេសាទ៖ វិញ្ញាបនបត្រវិជ្ជាជីវៈ*
- *កម្មករមិនមានជំនាញ អ្នកប្រកបមុខរបរតូចតាចៗ និងអ្នកធ្វើការផ្នែកកសិកម្ម ព្រៃឈើ និងនេសាទ៖ ការអប់រំមូលដ្ឋាន*

ក្នុងឆ្នាំ២០២៦ ទីផ្សារការងារកម្ពុជានឹងមានការវិវត្តយ៉ាងខ្លាំងក្លាឆ្ពោះទៅរកការប្រើប្រាស់ពលកម្មជំនាញ និងបច្ចេកទេសដើម្បីជំរុញផលិតភាពជាតិ។ ក្រុមកម្មករជំនាញ និងការីម៉ាស៊ីន (ISCO 7&8) មានតម្រូវការខ្ពស់ជាងគេហូតដល់ ២៧២ ៤៤២ នាក់ ដែលភាគច្រើនមកពីវិស័យកាត់ដេរ ស្បែកជើង និងកាបូប (GFT)។ សម្រាប់ក្រុមអ្នកគ្រប់គ្រង វិស្វករ និងអ្នកបច្ចេកទេស (ISCO 1, 2 & 3) ត្រូវ ការកម្លាំងពលកម្មប្រមាណជិត ៣ ម៉ឺននាក់ ដែលទាមទារឱ្យមានគុណវុឌ្ឍិខ្ពស់ចាប់ពីកម្រិតបច្ចេកទេសជាន់ខ្ពស់ឡើងទៅ។

ខាងក្រោមនេះគឺជាការបង្ហាញពីមុខរបរដែលកំពុងមានតម្រូវការច្រើនទៅតាមកម្រិតជំនាញ (ជំនាញឯកទេស គុណវុឌ្ឍិ និងអាជីព) ចំនួនការងារសរុប ស្ថានភាពនិងការប៉ាន់ស្មានឱកាសការងារ ការលំបាកក្នុងការជ្រើសរើសបុគ្គលិក ការផ្តល់ឱកាសសម្រាប់អ្នកគ្មានបទពិសោធន៍ កង្វះជំនាញ និងគម្លាតជំនាញតាមអនុវិស័យចម្បងទាំង ១៤។




***កំណត់ចំណាំ៖***

- *ព័ត៌មានចំនួនការងារ ចំនួនជ្រើសរើសបុគ្គលិក ការលំបាកក្នុងការជ្រើសរើសបុគ្គលិក ការផ្តល់ឱកាសឱ្យអ្នកគ្មានបទពិសោធន៍ ឱកាសការងារ កង្វះខាតជំនាញ និងបញ្ហាគម្លាតជំនាញ មានប្រភពមកពីរបាយការណ៍អង្កេតរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។*
- *ទិន្នន័យប្រាក់ឈ្នួលប្រចាំខែតាមអនុវិស័យជាប្រាក់ឈ្នួលគោលប្រចាំខែដោយមិនរាប់បញ្ចូលអត្ថប្រយោជន៍បន្ថែម ដូចជា៖ ប្រាក់កម្រៃជើងសារ, ប្រាក់សោហ៊ុយធ្វើដំណើរ និងស្នាក់នៅ, ប្រាក់រង្វាន់ធ្វើការទៀងទាត់, ប្រាក់ថ្លៃបាយ, ប្រាក់ឧបត្ថម្ភ និងប្រាក់រង្វាន់អតីតភាពការងារ ជាដើម។*

# អនុវិស័យស្នាក់នៅ និងភោជនីយដ្ឋាន

## ជំនាញខ្ពស់ (កម្រិត៣ និង៤)

គុណវុឌ្ឍិ៖ បរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ

| មុខជំនាញ | ISCED-F 2013 |
|---|---|
| ហិរញ្ញវត្ថុ និងធនាគារ | 0412 |
| សេដ្ឋកិច្ច និងគ្រប់គ្រង | 0311 |
| គ្រប់គ្រងពាណិជ្ជកម្ម | 0414 |
| គ្រប់គ្រង និងរដ្ឋបាល | 0413 |
| និតិសាស្ត្រ | 0421 |
| វិស្វកម្មកម្មវិធីកុំព្យូទ័រ និងពហុមេឌា | 0211 |
| សារព័ត៌មាន និងការរាយការណ៍ | 0321 |

**នាយកគ្រប់គ្រងការលក់ និងទីផ្សារ**
- 1000-1100 $
- បទពិសោធន៍ 5 ឆ្នាំឡើង
- ជំនាញទំនាក់ទំនង
- ជំនាញចរចា និងបញ្ចុះបញ្ចូល
- ដោះស្រាយបញ្ហា និងភាពបត់បែន

**នាយកគ្រប់គ្រងធនធានមនុស្ស**
- 450-470 $
- បទពិសោធន៍ 5 ឆ្នាំឡើង
- ជំនាញក្នុងការស្តាប់
- ជំនាញដោះស្រាយជម្លោះ
- ជំនាញទំនាក់ទំនង និងការចរចា

**អ្នកជំនាញផ្នែកផ្សព្វផ្សាយ និងទីផ្សារ**
- 400-450 $
- បទពិសោធន៍ 5 ឆ្នាំឡើង
- យល់ចិត្តអតិថិជន
- គំនិតបែបច្នៃប្រឌិត
- ធ្វើការងារជាក្រុម និងកិច្ចសហការ

## ជំនាញមធ្យម (កម្រិត២)

គុណវុឌ្ឍិ៖ មធ្យមសិក្សាទុតិយភូមិ ឬ សញ្ញាបត្របច្ចេកទេស & វិជ្ជាជីវៈ១ ២ និង៣ ឡើងទៅ

| មុខជំនាញ | ISCED-F 2013 |
|---|---|
| អគ្គិសនី | 0713 |
| អេឡិចត្រូនិក | 0714 |
| មេកានិក | 0715 |
| សំណង់ និងវិស្វកម្មស៊ីវិល | 0732 |
| ទេសចរណ៍ | 1015 |
| ភាសាបរទេស | 0231 |
| បដិសណ្ឋារកិច្ច | 1013 |
| សុខភាព និងសុវត្ថិភាពការងារ | 1022 |

**អ្នកបច្ចេកទេសខាងវិស្វកម្មគ្រឿងម៉ាស៊ីន**
- 500-600 $
- បទពិសោធន៍ 1-3 ឆ្នាំ
- ជំនាញទំនាក់ទំនង
- ការគ្រប់គ្រងពេលវេលា
- កិច្ចសហការ និងការងារក្រុម

**ជាងដំឡើង និងថែទាំជណ្ដើរយន្ត**
- 400-500 $
- បទពិសោធន៍ 1-3 ឆ្នាំ
- ការដោះស្រាយបញ្ហា
- ការគ្រប់គ្រងពេលវេលា
- កិច្ចសហការ និងការងារក្រុម

**អ្នកប្រឹក្សាយោបល់ និងបុគ្គលិកខាងការរៀបចំការធ្វើដំណើរ**
- 200-350 $
- បទពិសោធន៍ 3-5 ឆ្នាំ
- ហ្មត់ចត់
- ដោះស្រាយបញ្ហា
- ទំនាក់ទំនង និងការបញ្ចុះបញ្ចូល

**អ្នកទទួលភ្ញៀវក្នុងសណ្ឋាគារ**
- 200-280 $
- បទពិសោធន៍ 3 ឆ្នាំឡើង
- ភាពបត់បែន
- ការដោះស្រាយបញ្ហា
- បដិសណ្ឋារកិច្ច និងភាពរាក់ទាក់

## ជំនាញទាប (កម្រិត១)

**គុណវុឌ្ឍិ៖** មធ្យមសិក្សាបឋមភូមិ ឬ វិញ្ញាបនបត្រវិជ្ជាជីវៈឡើងទៅ

| មុខជំនាញ | ISCED-F 2013 |
|---|---|
| បើកបរយានយន្ត | 1041 |
| ការងារលេខាធិការដ្ឋាន និងការងារការិយាល័យ | 0415 |
| បដិសណ្ឋារកិច្ច | 1013 |
| សេវាបំរើតាមផ្ទះ | 1011 |
| សុខភាព និងសុវត្ថិភាពការងារ | 1022 |

**អ្នកនាំសារ អ្នកដឹកជញ្ជូនកញ្ចប់ឥវ៉ាន់ និងអ្នកជួយយ៉ូវ៉ាលី**

- 230-240 $
- បទពិសោធន៍: 0-3 ឆ្នាំ
- ភាពហ្មត់ចត់ និងទំនួលខុសត្រូវ
- ជំនាញទំនាក់ទំនង និងសុជីវធម៌
- គ្រប់គ្រងពេលវេលា និងទៀងទាត់

**អ្នកជួយការងារកន្លែងចម្អិនអាហារ**

- 200-220 $
- បទពិសោធន៍: 0-3 ឆ្នាំ
- អនាម័យ និងសុវត្ថិភាព
- ការទទួលយកការណែនាំ
- រហ័សរហួន និងការងារក្រោមសម្ពាធ

**អ្នកសម្អាតអនាម័យ និងអ្នកជួយធ្វើកិច្ចការផ្សេងៗក្នុងសហគ្រាស**

- 180-200 $
- បទពិសោធន៍: 0-3 ឆ្នាំ
- ភាពហ្មត់ចត់
- គ្រប់គ្រងពេលវេលា
- ភាពស្មោះត្រង់ និងជឿជាក់បាន

ចំនួនការងារសរុប: **82,912 នាក់**

ក្រុមហ៊ុនកំពុងប្រកាសជ្រើសរើស (%នៃក្រុមហ៊ុនសរុប): **43.89 %**

ការប៉ាន់ស្មានចំនួនជ្រើសរើសបុគ្គលិក: **3,681 កន្លែង**

ការលំបាកក្នុងការជ្រើសរើសបុគ្គលិក (%នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក): **22.20 %**

ក្រុមហ៊ុនផ្ដល់ឱកាសឲ្យអ្នកគ្មានបទពិសោធន៍ (%នៃក្រុមហ៊ុនសរុប): **10.00 %**

ឱកាសការងារក្នុងអនុវិស័យនេះ: **3.55**

រាជធានីខេត្តទាំង ៣ ដែលមានតម្រូវការការងារខ្ពស់




កង្វះខាតជំនាញ (% នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក): **1.99 %**

ក្រុមហ៊ុនដែលជួបបញ្ហាគម្លាតជំនាញ (%នៃក្រុមហ៊ុនសរុប): **28.84 %**

# អនុវិស័យអប់រំ

## ជំនាញខ្ពស់ (កម្រិត៣ និង៤)

គុណវុឌ្ឍិ៖ បរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ

| មុខជំនាញ | ISCED-F 2013 |
| --- | --- |
| គ្រប់គ្រង និងរដ្ឋបាល | 0413 |
| សេដ្ឋកិច្ច និងគ្រប់គ្រង | 0311 |
| និតិសាស្ត្រ | 0421 |
| គិលានុបដ្ឋាក | 0913 |
| ចំណេះដឹងវេជ្ជសាស្ត្រ | 0912 |
| ការព្យាបាលដោយចលនា | 0915 |
| គ្រប់គ្រងពាណិជ្ជកម្ម | 0414 |
| វិស្វកម្មកម្មវិធីកុំព្យូទ័រ និងពហុមេឌា | 0211 |
| សារព័ត៌មាន និងការរាយការណ៍ | 0321 |

**នាយកគ្រប់គ្រងធនធានមនុស្ស** (0413, 0311, 0421)
- 600-700$
- បទពិសោធន៍ 5 ឆ្នាំឡើង
- ជំនាញទំនាក់ទំនង
- ជំនាញដោះស្រាយវិវាទ
- ជំនាញចរចា និងបញ្ចុះបញ្ចូល

**សហការីផ្នែកគិលានុបដ្ឋាយិកា** (0913, 0912, 0915)
- 350-550 $
- បទពិសោធន៍ 3-5 ឆ្នាំឡើង
- ភាពហ៊ានប្រថុយ
- ជំនាញទំនាក់ទំនង
- អត់ធ្មត់ និងការគ្រប់គ្រងអារម្មណ៍

**អ្នកជំនាញផ្នែកផ្សព្វផ្សាយ និងទីផ្សារ** (0414, 0211, 0321)
- 350-400 $
- បទពិសោធន៍ 3 ឆ្នាំឡើង
- ភាពបត់បែន
- ការបញ្ចុះបញ្ចូល
- ការនិយាយជាសាធារណៈ

## ជំនាញមធ្យម (កម្រិត២)

គុណវុឌ្ឍិ៖ មធ្យមសិក្សាទុតិយភូមិ ឬ សញ្ញាបត្របច្ចេកទេស & វិជ្ជាជីវៈ១ ២ និង៣ ឡើងទៅ

| មុខជំនាញ | ISCED-F 2013 |
| --- | --- |
| បណ្តាញ និងការគ្រប់គ្រងមូលដ្ឋានទិន្នន័យ និងបណ្តាញ | 0612 |
| អគ្គិសនី | 0713 |
| អេឡិចត្រូនិក | 0714 |
| រៀនបើកបរយានយន្ត | 1041 |
| សុខភាព និងសុវត្ថិភាពការងារ | 1022 |
| យានយន្ត | 0716 |
| ក្សាសុវត្ថិភាព | 1032 |
| សំណង់ | 0732 |
| កម្មវិធីកុំព្យូទ័រ | 0611 |
| ការងារលេខាធិការដ្ឋាន និងការងារការិយាល័យ | 0415 |
| បំណិន និងការអភិវឌ្ឍបុគ្គល | 0031 |

**អ្នកតម្លើង និងអ្នកផ្តល់សេវាបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា** (0612, 0713, 0714)
- 330-520 $
- បទពិសោធន៍ 3 ឆ្នាំ
- ការយល់ដឹងពីសុវត្ថិភាព
- អត់ធ្មត់ និងការគ្រប់គ្រងអារម្មណ៍
- យកចិត្តទុកដាក់ និងស្មារតីប្រុងប្រយ័ត្ន

**អ្នកបើកបររថយន្តតូច រថយន្តឈ្នួល និងរថយន្តវែន** (1041, 1022, 0716)
- 270-315 $
- បទពិសោធន៍ 3 ឆ្នាំឡើង
- ទំនាក់ទំនង និងសេវាកម្មអតិថិជន
- គ្រប់គ្រងពេលវេលា
- យកចិត្តទុកដាក់ និងស្មារតីប្រុងប្រយ័ត្ន

**អ្នកមើលការខុសត្រូវអាគារ** (1022, 1032, 0732)
- 230-250 $
- បទពិសោធន៍ 1 ឆ្នាំ
- ក្សាសុវត្ថិភាព
- ទទួលខុសត្រូវ
- ជំនាញទំនាក់ទំនង

**លេខាធិការ (ទូទៅ)** (0611, 0415, 0031)
- 250-300 $
- បទពិសោធន៍ 2 ឆ្នាំ
- ភាពបត់បែន
- ជំនាញទំនាក់ទំនង
- គ្រប់គ្រងពេលវេលា

## ជំនាញទាប (កម្រិត១)

គុណវុឌ្ឍិ៖ មធ្យមសិក្សាបឋមភូមិ ឬ វិញ្ញាបនបត្រវិជ្ជាជីវៈឡើងទៅ

| មុខជំនាញ | ISCED-F 2013 |
|---|---|
| ជំនាញដែលមិនបានធ្វើចំណាត់ថ្នាក់ (ប្រើឧបករណ៍សម្អាត) | 0719 |
| សេវាបំរើតាមផ្ទះ | 1011 |
| សុវត្ថិភាព និងសុខភាពការងារ | 1022 |
| បដិសណ្ឋារកិច្ច | 1013 |
| បើកបរយានយន្ត | 1041 |
| សេវាកម្មក្នុងផ្ទះ និងសហគ្រាស | 1011 |

**អ្នកសម្អាតអនាម័យ និងអ្នកជួយធ្វើកិច្ចការផ្សេងៗក្នុងសហគ្រាស**

- 200-250 $
- បទពិសោធន៍ 0-3 ឆ្នាំ
- គ្រប់គ្រងពេលវេលា
- ស្មោះត្រង់ និងភាពជឿជាក់បាន
- ភាពហ្មត់ចត់ និងការយកចិត្តទុកដាក់លើព័ត៌មានលម្អិត

**អ្នកជួយការងារកន្លែងចម្អិនអាហារ**

- 200-220 $
- បទពិសោធន៍ 1 ឆ្នាំ
- ជំនាញក្នុងការស្តាប់
- យកចិត្តទុកដាក់លើអនាម័យ និងសុវត្ថិភាព
- រហ័សរហួន និងការធ្វើការងារក្រោមសម្ពាធ

**អ្នកនាំសារ អ្នកដឹកជញ្ជូនកញ្ចប់ឥវ៉ាន់ និងអ្នកជួយឃួរ៉ាលី**

- 280-330 $
- បទពិសោធន៍ 0 - 2 ឆ្នាំ
- ការគោរពវិន័យ និងពេលវេលា
- ការស្តាប់ និងអនុវត្តតាមការណែនាំ
- ការយល់ដឹងពីសុវត្ថិភាព

ចំនួនការងារសរុប: 33,160 នាក់

ក្រុមហ៊ុនកំពុងប្រកាសជ្រើសរើស (%នៃក្រុមហ៊ុនសរុប): 69.99 %

ការប៉ាន់ស្មានចំនួនជ្រើសរើសបុគ្គលិក: 1,641 កន្លែង

ការលំបាកក្នុងការជ្រើសរើសបុគ្គលិក (%នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក): 10.19 %

ក្រុមហ៊ុនផ្តល់ឱកាសឲ្យអ្នកគ្មានបទពិសោធន៍ (%នៃក្រុមហ៊ុនសរុប): 28.29 %

ឱកាសការងារក្នុងអនុវិស័យនេះ: 3.22

រាជធានីខេត្តទាំង ៣ ដែលមានតម្រូវការការងារខ្ពស់




កង្វះខាតជំនាញ (% នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក): 6.68 %

ក្រុមហ៊ុនដែលជួបបញ្ហាគម្លាតជំនាញ (%នៃក្រុមហ៊ុនសរុប): 30.87 %

# អនុវិស័យហិរញ្ញវត្ថុ និងធនាគាររ៉ាប់រង

## ជំនាញខ្ពស់ (កម្រិត៣ និង៤)

គុណវុឌ្ឍិ៖ បរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ

| មុខជំនាញ | ISCED-F 2013 |
|---|---|
| ហិរញ្ញវត្ថុ ធនាគារ និងធានារ៉ាប់រង | 0412 |
| សេដ្ឋកិច្ច និងគ្រប់គ្រង | 0311 |
| ការគ្រប់គ្រង និងរដ្ឋបាល | 0413 |
| ជំនាញក្នុងការងារ | 0417 |
| គ្រប់គ្រងពាណិជ្ជកម្ម | 0414 |
| បច្ចេកទេសសោតទស្សន៍ និងការផលិតមេឌៀ | 0211 |
| សារព័ត៌មាន និងការរាយការណ៍ | 0321 |

**ឈ្មួញ និងឈ្មួញកណ្ដាលខាងមូលប័ត្រ និងហិរញ្ញវត្ថុ**
- 310-500 $
- បទពិសោធន៍: 3 ឆ្នាំឡើង
- ប្រាស្រ័យទាក់ទង
- ភាពស្មោះត្រង់ក្នុងវិជ្ជាជីវៈ
- ការធ្វើសេចក្ដីសម្រេចចិត្ត

**នាយកគ្រប់គ្រងសេវាអាជីពដែលមិនបានធ្វើចំណាត់ថ្នាក់**
- 800-1100$
- បទពិសោធន៍: 5 ឆ្នាំឡើង
- ភាពជាអ្នកដឹកនាំ
- ការធ្វើការងារជាក្រុម
- ការគិតបែបយុទ្ធសាស្ត្រ

**អ្នកជំនាញផ្នែកផ្សព្វផ្សាយ និងទីផ្សារ**
- 350-500 $
- បទពិសោធន៍: 3 ឆ្នាំឡើង
- ភាពបត់បែន
- ការបញ្ចុះបញ្ចូល
- ការនិយាយជាសាធារណៈ

## ជំនាញមធ្យម (កម្រិត២)

គុណវុឌ្ឍិ៖ មធ្យមសិក្សាទុតិយភូមិ ឬ សញ្ញាបត្របច្ចេកទេស & វិជ្ជាជីវៈ១ ២ និង៣ ឡើងទៅ

| មុខជំនាញ | ISCED-F 2013 |
|---|---|
| ការរចនា, គ្រប់គ្រងមូលដ្ឋានទិន្នន័យ និង បណ្ដាញ | 0612 |
| អគ្គិសនី និងអេឡិចត្រូនិច | 0713 |
| មេកានិក | 0715 |
| គ្រប់គ្រងពាណិជ្ជកម្ម | 0414 |
| ទីផ្សារ | 0416 |
| រៀនបើកបរយានយន្ត | 1041 |
| យានយន្ត | 0716 |
| សុខភាព និងសុវត្ថិភាពការងារ | 1022 |
| កម្មវិធីកុំព្យូទ័រ | 0611 |
| ភាសាបរទេស | 0114 |
| ការងារលេខាធិការដ្ឋាន និងរដ្ឋបាលការិយាល័យ | 0415 |

**អ្នកតម្លើង និងអ្នកផ្ដល់សេវាបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា**
- 330-520 $
- បទពិសោធន៍: 3 ឆ្នាំឡើងទៅ
- ការអត់ធ្មត់
- ប្រាស្រ័យទាក់ទងបច្ចេកទេស
- ដោះស្រាយបញ្ហាបច្ចេកទេស

**អ្នកលក់ ឬអ្នកទីផ្សារតាមទូរស័ព្ទ**
- 300-320 $
- បទពិសោធន៍: 0-2 ឆ្នាំ
- ជំនាញបញ្ចុះបញ្ចូល
- ការនិយាយច្បាស់ៗ
- ការគ្រប់គ្រងអារម្មណ៍

**អ្នកបើកបររថយន្តតូច រថយន្តឈ្នួល និងរថយន្តវែន**
- 270-280 $
- បទពិសោធន៍: 3 ឆ្នាំឡើង
- គ្រប់គ្រងពេលវេលា
- ទំនាក់ទំនង និងសេវាកម្មអតិថិជន
- យកចិត្តទុកដាក់ និងស្មារតីប្រុងប្រយ័ត្ន

**បុគ្គលិកបញ្ចូលទិន្នន័យ**
- 250-280 $
- បទពិសោធន៍: 0-2 ឆ្នាំ
- ល្បឿនវាយអត្ថបទ
- ការរក្សាការសម្ងាត់
- ការគ្រប់គ្រងឯកសារ

**ជំនាញទាប(កម្រិត១)** — គុណវុឌ្ឍិ៖ មធ្យមសិក្សាបឋមភូមិ ឬ វិញ្ញាបនបត្រវិជ្ជាជីវៈឡើងទៅ

| មុខជំនាញ | ISCED-F 2013 |
|---|---|
| សេវាបំរើតាមផ្ទះ | 1011 |
| សុខភាព និងសុវត្ថិភាពការងារ | 1022 |
| បដិសណ្ឋារកិច្ច | 1013 |
| សេវាដឹកជញ្ជូន | 1041 |
| លេខាធិការ និងការងារការិយាល័យ | 0415 |
| ជំនាញដែលមិនបានធ្វើចំណាត់ថ្នាក់ (ប្រើឧបករណ៍សម្អាត) | 0719 |

| មុខរបរ | ប្រាក់ខែ | បទពិសោធន៍ | ជំនាញ |
|---|---|---|---|
| អ្នកជួយការងារកន្លែងចម្អិនអាហារ | 200-220 $ | 0-3 ឆ្នាំ | • ស្តាប់ និងការទទួលយកការណែនាំ<br>• យកចិត្តទុកដាក់លើអនាម័យ និងសុវត្ថិភាព<br>• ភាពរហ័សរហួន និងការធ្វើការងារក្រោមសម្ពាធ |
| អ្នកនាំសារ អ្នកដឹកជញ្ជូនកញ្ចប់ឥវ៉ាន់ និងអ្នកជួយយួរវ៉ាលី | 178-230 $ | 0-3 ឆ្នាំ | • ជំនាញទំនាក់ទំនង និងសុជីវធម៌<br>• ភាពហ្មត់ចត់ និងការទទួលខុសត្រូវ<br>• គ្រប់គ្រងពេលវេលា និងភាពទៀងទាត់ |
| អ្នកសម្អាតអនាម័យ និងអ្នកជួយធ្វើកិច្ចការផ្សេងៗក្នុងសហគ្រាស | 180-200 $ | 0-3 ឆ្នាំ | • គ្រប់គ្រងពេលវេលា<br>• ភាពស្មោះត្រង់ និងភាពជឿជាក់បាន<br>• ភាពហ្មត់ចត់ និងការយកចិត្តទុកដាក់លើព័ត៌មានលម្អិត |

**ចំនួនការងារសរុប** — 107,471 នាក់

**ក្រុមហ៊ុនកំពុងប្រកាសជ្រើសរើស (%នៃក្រុមហ៊ុនសរុប)** — 56.20 %

**ការប៉ាន់ស្មានចំនួនជ្រើសរើសបុគ្គលិក** — 7,801 កន្លែង

**ការលំបាកក្នុងការជ្រើសរើសបុគ្គលិក (%នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក)** — 30.75 %

**ក្រុមហ៊ុនផ្តល់ឱកាសឲ្យអ្នកគ្មានបទពិសោធន៍(%នៃក្រុមហ៊ុនសរុប)** — 16.21 %

**ឱកាសការងារក្នុងអនុវិស័យនេះ** — 3.25

**រាជធានីខេត្តទាំង ៣ ដែលមានតម្រូវការការងារខ្ពស់**




**កង្វះខាតជំនាញ (% នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក)** — 13.27 %

**ក្រុមហ៊ុនដែលជួបបញ្ហាគម្លាតជំនាញ (%នៃក្រុមហ៊ុនសរុប)** — 23.52 %

# អនុវិស័យសេវាសុខាភិបាល

## ជំនាញខ្ពស់ (កម្រិត៣ និង៤)

គុណវុឌ្ឍិ៖ បរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ

| មុខជំនាញ | ISCED-F 2013 |
|---|---|
| គ្រប់គ្រងពាណិជ្ជកម្ម | 0414 |
| ហិរញ្ញវត្ថុ និងធនាគារ | 0412 |
| សេដ្ឋកិច្ច និងគ្រប់គ្រង | 0311 |
| ចំណេះដឹងវេជ្ជសាស្ត្រ | 0912 |
| ការថែទាំ | 0922 |
| បច្ចេកទេសមន្ទីរពិសោធន៍ | 0914 |
| គិលានុបដ្ឋាក | 0913 |
| ការព្យាបាលដោយចលនា | 0915 |
| ឱសថសាស្ត្រ | 0916 |

**នាយកគ្រប់គ្រងការលក់ និងទីផ្សារ** (0414, 0412, 0311)
- 1150-1300 $
- បទពិសោធន៍ 5-8 ឆ្នាំ
- ភាពជាអ្នកដឹកនាំ
- សីលធម៌វិជ្ជាជីវៈ
- ការគិតបែបវិភាគ

**ជំនួយការពេទ្យ** (0912, 0922, 0914)
- 750-850 $
- បទពិសោធន៍ 3-5 ឆ្នាំ
- ជំនាញទំនាក់ទំនង
- ការដោះស្រាយបញ្ហា
- ការគ្រប់គ្រងពេលវេលា

**វិជ្ជាជីវៈជាសហការីផ្នែកគិលានុបដ្ឋាយិកា** (0913, 0915, 0916)
- 350-450 $
- បទពិសោធន៍ 1-3 ឆ្នាំ
- ជំនាញទំនាក់ទំនង
- ការដោះស្រាយបញ្ហា
- ការគ្រប់គ្រងពេលវេលា

## ជំនាញមធ្យម (កម្រិត២)

គុណវុឌ្ឍិ៖ មធ្យមសិក្សាទុតិយភូមិ ឬ សញ្ញាបត្របច្ចេកទេស & វិជ្ជាជីវៈ១ ២ និង៣ ឡើងទៅ

| មុខជំនាញ | ISCED-F 2013 |
|---|---|
| ការការពារបុគ្គល និងទ្រព្យសម្បត្តិ | 1032 |
| វិស្វកម្មសំណង់ស៊ីវិល និងអាគារ | 0732 |
| យានយន្ត | 0716 |
| ការគ្រប់គ្រង និងរដ្ឋបាល | 0413 |
| សុខភាព និងសុវត្ថិភាពការងារ | 1022 |
| បើកបរយានយន្ត | 1041 |
| កម្មវិធីកុំព្យូទ័រ | 0611 |
| អេឡិចត្រូនិក | 0714 |
| សេវាបណ្ដាញ និងរដ្ឋបាលប្រព័ន្ធ | 0612 |

**អ្នកមើលការខុសត្រូវអាគារ**
- 450-500 $
- បទពិសោធន៍ 3-5 ឆ្នាំ
- ជំនាញទំនាក់ទំនង
- ការដោះស្រាយបញ្ហា
- ការគ្រប់គ្រងពេលវេលា

**លេខាធិការ (ទូទៅ)**
- 400-500 $
- បទពិសោធន៍ 3-5 ឆ្នាំ
- ជំនាញទំនាក់ទំនង
- ការដោះស្រាយបញ្ហា
- ការគ្រប់គ្រងពេលវេលា

**អ្នកបើកបររថយន្តតូច រថយន្តឈ្នួល និងរថយន្តវែន**
- 300-450 $
- បទពិសោធន៍ 2-3 ឆ្នាំ
- ជំនាញទំនាក់ទំនង
- ការគ្រប់គ្រងពេលវេលា
- ការគោរពវិន័យ និងអនាម័យ

**អ្នកតម្លើង និងអ្នកផ្ដល់សេវាបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា**
- 400-450 $
- បទពិសោធន៍ 3 ឆ្នាំឡើង
- ជំនាញទំនាក់ទំនង
- ការដោះស្រាយបញ្ហា
- ការគ្រប់គ្រងពេលវេលា

**ជំនាញទាប(កម្រិត១)** — គុណវុឌ្ឍិ៖ មធ្យមសិក្សាបឋមភូមិ ឬ វិញ្ញាបនបត្រវិជ្ជាជីវៈឡើងទៅ

| មុខជំនាញ | ISCED-F 2013 |
| --- | --- |
| បើកបរយានយន្ត | 1041 |
| លេខាធិការ និងការងារការិយាល័យ | 0415 |
| សេវាកម្មក្នុងផ្ទះ និងសហគ្រាស | 1011 |
| បដិសណ្ឋារកិច្ច | 1013 |
| ការកែច្នៃអាហារ | 0721 |
| សុខភាព និងសុវត្ថិភាពការងារ | 1022 |

**អ្នកនាំសារ អ្នកដឹកជញ្ជូនកញ្ចប់ឥវ៉ាន់ និងអ្នកជួយយួរវ៉ាលី**
- 280-330 $
- បទពិសោធន៍ 0-2 ឆ្នាំ
- ការយល់ដឹងពីសុវត្ថិភាព
- ការគោរពវិន័យ និងពេលវេលា
- ការស្តាប់ និងអនុវត្តតាមការណែនាំ

**អ្នកជួយការងារកន្លែងចម្អិនអាហារ**
- 250-300 $
- បទពិសោធន៍ 0-2 ឆ្នាំ
- ការយល់ដឹងពីសុវត្ថិភាព
- ការគោរពវិន័យ និងពេលវេលា
- ការស្តាប់ និងអនុវត្តតាមការណែនាំ

**អ្នកសម្អាតអនាម័យ និងអ្នកជួយធ្វើកិច្ចការផ្សេងៗក្នុងសហគ្រាស**
- 250-300 $
- បទពិសោធន៍ 0-2 ឆ្នាំ
- ការយល់ដឹងពីសុវត្ថិភាព
- ការគោរពវិន័យ និងពេលវេលា
- ការស្តាប់ និងអនុវត្តតាមការណែនាំ

ចំនួនការងារសរុប
9,211 នាក់

ក្រុមហ៊ុនកំពុងប្រកាសជ្រើសរើស (%នៃក្រុមហ៊ុនសរុប)
42.34 %

ការប៉ាន់ស្មានចំនួនជ្រើសរើសបុគ្គលិក
576 កន្លែង

ការលំបាកក្នុងការជ្រើសរើសបុគ្គលិក (%នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក)
40.63 %

ក្រុមហ៊ុនផ្តល់ឱកាសឲ្យអ្នកគ្មានបទពិសោធន៍ (%នៃក្រុមហ៊ុនសរុប)
13.42 %

ឱកាសការងារក្នុងអនុវិស័យនេះ
3.69

រាជធានីខេត្តទាំង ៣ ដែលមានតម្រូវការការងារខ្ពស់




កង្វះខាតជំនាញ (% នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក)
33.48 %

ក្រុមហ៊ុនដែលជួបបញ្ហាគម្លាតជំនាញ (%នៃក្រុមហ៊ុនសរុប)
10.40 %

# អនុវិស័យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT)

## ជំនាញខ្ពស់(កម្រិត៣ និង៤)

គុណវុឌ្ឍិ៖ បរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ

| មុខជំនាញ | ISCED-F 2013 |
|---|---|
| ការរចនា,គ្រប់គ្រងមូលដ្ឋានទិន្នន័យ និងបណ្តាញ | 0612 |
| សរសេរកម្មវិធីបញ្ហា និងវិភាគប្រព័ន្ធ | 0613 |
| អេឡិចត្រូនិក | 0714 |
| អគ្គិសនី | 0713 |
| គ្រប់គ្រងពាណិជ្ជកម្ម | 0414 |
| គ្រប់គ្រង និងរដ្ឋបាល | 0413 |
| គ្រប់គ្រងប្រតិបត្តិការលក់ និង ការកំណត់តម្លៃ | 0416 |

**វិស្វករអេឡិចត្រូនិច**
- 1000-1200 $
- បទពិសោធន៍ 3-5 ឆ្នាំ
- ការគ្រប់គ្រងពេលវេលា
- ជំនាញទំនាក់ទំនង និងការធ្វើការងារជាក្រុម
- ការគិតបែបវិភាគ និងដោះស្រាយបញ្ហា

**អ្នកបច្ចេកទេសខាងវិស្វកម្មអេឡិចត្រូនិច**
- 700-900 $
- បទពិសោធន៍ 2-4 ឆ្នាំ
- ការធ្វើការងារជាក្រុម
- ការដោះស្រាយបញ្ហា
- ការគ្រប់គ្រងពេលវេលា

**នាយកគ្រប់គ្រងការលក់ និងទីផ្សារ**
- 500-600 $
- បទពិសោធន៍ 2-4 ឆ្នាំ
- ជំនាញចរចា និងបញ្ចុះបញ្ចូល
- ការដោះស្រាយបញ្ហាអតិថិជន
- ការធ្វើការងារជាក្រុម

## ជំនាញមធ្យម(កម្រិត២)

គុណវុឌ្ឍិ៖ មធ្យមសិក្សាទុតិយភូមិ ឬ សញ្ញាបត្របច្ចេកទេស & វិជ្ជាជីវៈ១ ២ និង៣ ឡើងទៅ

| មុខជំនាញ | ISCED-F 2013 |
|---|---|
| យន្តការ និងជំនាញលោហៈ | 0715 |
| អគ្គិសនី | 0713 |
| អេឡិចត្រូនិក | 0714 |
| ការងារលេខាធិការដ្ឋាន និង ការងារការិយាល័យ | 0415 |
| កម្មវិធីកុំព្យូទ័រ | 0611 |
| ជំនាញការងារ | 0011 |
| សុខភាព និងសុវត្ថិភាពការងារ | 1022 |
| មូលដ្ឋានទិន្នន័យ និងការគ្រប់គ្រងបណ្តាញ | 0612 |
| សូហ្វវែរ និងការអភិវឌ្ឍកម្មវិធី | 0613 |

**អ្នកតម្លើងបរិក្ខារអគ្គីសនី និងអេឡិចត្រូនិច**
- 300-400 $
- បទពិសោធន៍ 2-5 ឆ្នាំ
- ការធ្វើការងារជាក្រុម
- ការដោះស្រាយបញ្ហា
- ការគ្រប់គ្រងពេលវេលា

**យន្តការី និងអ្នកតម្លើងអគ្គីសនី**
- 320-410 $
- បទពិសោធន៍ 2-5 ឆ្នាំ
- ការធ្វើការងារជាក្រុម
- ការដោះស្រាយបញ្ហា
- ការគ្រប់គ្រងពេលវេលា

**បុគ្គលិកបញ្ចូលទិន្នន័យ**
- 250-350 $
- បទពិសោធន៍ 0-3 ឆ្នាំ
- ការសហការ
- ជំនាញទំនាក់ទំនង
- ការគ្រប់គ្រងពេលវេលា

**អ្នកតម្លើង និងអ្នកផ្តល់សេវាបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា**
- 300-400 $
- បទពិសោធន៍ 1-3 ឆ្នាំ
- ការធ្វើការងារជាក្រុម
- ការដោះស្រាយបញ្ហា
- ជំនាញទំនាក់ទំនង

**ជំនាញទាប (កម្រិត១)** — គុណវុឌ្ឍិ៖ មធ្យមសិក្សាបឋមភូមិ ឬ វិញ្ញាបនបត្រវិជ្ជាជីវៈឡើងទៅ

| មុខជំនាញ | ISCED-F 2013 |
|---|---|
| ជំនាញដែលមិនបានធ្វើចំណាត់ថ្នាក់ (ដាក់ និងរៀបអីវ៉ាន់) | 0619 |
| ការលក់ដុំ និងការលក់រាយ (ការគ្រប់គ្រងស្តុក និងឃ្លាំង) | 0416 |
| សេវាកម្មដឹកជញ្ជូន | 1041 |
| ជំនាញការងារ | 0417 |
| សុខភាព និងសុវត្ថិភាពការងារ | 1022 |
| សេវាបំរើតាមផ្ទះ | 1011 |
| បដិសណ្ឋារកិច្ច | 1013 |

**អ្នករៀបដាក់ទំនិញតាមធ្នើក្នុងឃ្លាំង**
- 240-290 $
- បទពិសោធន៍ 0-2 ឆ្នាំ
- ភាពស្មោះត្រង់ និងវិន័យ
- ភាពម៉ឺងម៉ាត់ និងកម្លាំងកាយ
- ភាពហ្មត់ចត់ និងសណ្តាប់ធ្នាប់

**អ្នកនាំសារ អ្នកដឹកជញ្ជូនកញ្ចប់ឥវ៉ាន់ និងអ្នកជួយយូរវ៉ាលី**
- 200-250 $
- បទពិសោធន៍ 0-2 ឆ្នាំ
- ភាពម៉ឺងម៉ាត់ និងការគោរពវិន័យ
- ការយកចិត្តទុកដាក់លើអនាម័យ
- ភាពស្មោះត្រង់ និងការសហការ

**អ្នកសម្អាតអនាម័យ និងអ្នកជួយធ្វើកិច្ចការផ្សេងៗក្នុងសហគ្រាស**
- 200-250 $
- បទពិសោធន៍ 0-2 ឆ្នាំ
- ការគ្រប់គ្រងពេលវេលា
- ការយល់ដឹងពីសុវត្ថិភាពចរាចរណ៍
- ភាពស្មោះត្រង់ និងការទទួលខុសត្រូវ

**ចំនួនការងារសរុប**
17,237 នាក់

**ក្រុមហ៊ុនកំពុងប្រកាសជ្រើសរើស (%នៃក្រុមហ៊ុនសរុប)**
49.33 %

**ការប៉ាន់ស្មានចំនួនជ្រើសរើសបុគ្គលិក**
1,580 កន្លែង

**ការលំបាកក្នុងការជ្រើសរើសបុគ្គលិក (%នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក)**
11.14 %

**ក្រុមហ៊ុនផ្តល់ឱកាសឲ្យអ្នកគ្មានបទពិសោធន៍ (%នៃក្រុមហ៊ុនសរុប)**
26.50 %

**ឱកាសការងារក្នុងអនុវិស័យនេះ**
LOW SKILL HIGH 2.67

**រាជធានីខេត្តទាំង ៣ ដែលមានតម្រូវការការងារខ្ពស់**




**កង្វះខាតជំនាញ (% នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក)**
0.50 %

**ក្រុមហ៊ុនដែលជួបបញ្ហាគម្លាតជំនាញ (%នៃក្រុមហ៊ុនសរុប)**
17.09 %

# អនុវិស័យដឹកជញ្ជូន និងស្តុកទំនិញ

## ជំនាញខ្ពស់ (កម្រិត៣ និង៤)

គុណវុឌ្ឍិ៖ បរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ

| មុខជំនាញ | ISCED-F 2013 |
|---|---|
| សេដ្ឋកិច្ច និងគ្រប់គ្រង | 0311 |
| ជំនាញដែលមិនបានធ្វើចំណាត់ថ្នាក់ (អ្នកគ្រប់គ្រងផ្នែកជួសជុល) | 0719 |
| អេឡិចត្រូនិក | 0714 |
| វិទ្យាសាស្ត្ររូបវន្ត ដែលមិនបានធ្វើចំណាត់ថ្នាក់ | 0539 |
| គ្រប់គ្រងពាណិជ្ជកម្ម | 0414 |
| ការគ្រប់គ្រង និងរដ្ឋបាល | 0413 |
| ហិរញ្ញវត្ថុ និងធនាគារ | 0412 |

**នាយកគ្រប់គ្រងការលក់ និងទីផ្សារ**
- 600-700 $
- បទពិសោធន៍ 3-5 ឆ្នាំ
- ការធ្វើការងារជាក្រុម
- ជំនាញទំនាក់ទំនង
- ការគ្រប់គ្រងពេលវេលា

**អ្នកបច្ចេកទេសខាងវិទ្យាសាស្ត្ររូប និងវិស្វកម្ម ដែលមិនបានធ្វើចំណាត់ថ្នាក់**
- 500-600 $
- បទពិសោធន៍ 3-5 ឆ្នាំ
- ការគ្រប់គ្រងពេលវេលា
- ការគិតបែបវិភាគ និងដោះស្រាយបញ្ហា
- ជំនាញទំនាក់ទំនង និងការធ្វើការងារជាក្រុម

**វិជ្ជាជីវៈខាងការផ្សព្វផ្សាយ និងទីផ្សារ**
- 350-450 $
- បទពិសោធន៍ 3-5 ឆ្នាំ
- ជំនាញទំនាក់ទំនង
- ការគិតបែបវិភាគ
- ការច្នៃប្រឌិត

## ជំនាញមធ្យម (កម្រិត២)

គុណវុឌ្ឍិ៖ មធ្យមសិក្សាទុតិយភូមិ ឬ សញ្ញាបត្របច្ចេកទេស & វិជ្ជាជីវៈ១ ២ និង៣ ឡើងទៅ

| មុខជំនាញ | ISCED-F 2013 |
|---|---|
| សេវាបណ្តាញ និងរដ្ឋបាលប្រព័ន្ធ | 0612 |
| អេឡិចត្រូនិក | 0714 |
| កម្មវិធីកុំព្យូទ័រ | 0611 |
| សេវាកម្មដឹកជញ្ជូន | 1041 |
| យានយន្ត នាវា និងយន្តហោះ | 0716 |
| សុខភាព និងសុវត្ថិភាពការងារ | 1022 |
| ការងារលេខាធិការ និងការងារការិយាល័យ | 0415 |
| ភាសាបរទេស | 0231 |
| វិស្វកម្មសំណង់ស៊ីវិល និងអាគារ | 0732 |
| ជំនាញដែលមិនបានធ្វើចំណាត់ថ្នាក់ (អ្នកគ្រប់គ្រងអាគារ) | 0919 |
| ការការពារបុគ្គល និងទ្រព្យសម្បត្តិ | 1032 |

**អ្នកតម្លើង និងអ្នកផ្តល់សេវាបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា**
- 300-400 $
- បទពិសោធន៍ 2-3 ឆ្នាំ
- ជំនាញទំនាក់ទំនង
- ការដោះស្រាយបញ្ហា
- ការគ្រប់គ្រងពេលវេលា

**អ្នកបើកបររថយន្តដឹកទំនិញ និងរថយន្តដឹកទំនិញធុនធ្ងន់**
- 300-350 $
- បទពិសោធន៍ 2-5 ឆ្នាំ
- ការយល់ដឹងពីសុវត្ថិភាព
- ការដោះស្រាយបញ្ហា
- ការគ្រប់គ្រងពេលវេលា

**បុគ្គលិកបញ្ចូលទិន្នន័យ**
- 300-350 $
- បទពិសោធន៍ 0-3 ឆ្នាំ
- ការសហការ
- ការដោះស្រាយបញ្ហា
- ការគ្រប់គ្រងពេលវេលា

**អ្នកមើលការខុសត្រូវអាគារ**
- 300-350 $
- បទពិសោធន៍ 1-3 ឆ្នាំ
- ការដោះស្រាយបញ្ហា
- ជំនាញទំនាក់ទំនង
- ការគ្រប់គ្រងពេលវេលា




ចំនួនការងារសរុប

**19,561 នាក់**

ក្រុមហ៊ុនកំពុងប្រកាសជ្រើសរើស (%នៃក្រុមហ៊ុនសរុប)

**47.12 %**

ការប៉ាន់ស្មានចំនួនជ្រើសរើសបុគ្គលិក

**3,591 កន្លែង**

ការលំបាកក្នុងការជ្រើសរើសបុគ្គលិក (%នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក)

**23.81 %**

ក្រុមហ៊ុនផ្ដល់ឱកាសឲ្យអ្នកគ្មានបទពិសោធន៍(%នៃក្រុមហ៊ុនសរុប)

**16.29 %**

ឱកាសការងារក្នុងអនុវិស័យនេះ

**3.25**

រាជធានីខេត្តទាំង ៣ ដែលមានតម្រូវការការងារខ្ពស់




កង្វះខាតជំនាញ (% នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក)

**17.81 %**

ក្រុមហ៊ុនដែលជួបបញ្ហាគម្លាតជំនាញ (%នៃក្រុមហ៊ុនសរុប)

**6.93 %**

# អនុវិស័យសំណង់

## ជំនាញខ្ពស់(កម្រិត៣ និង៤) — គុណវុឌ្ឍិ៖ បរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ

| មុខជំនាញ | ISCED-F 2013 |
|---|---|
| គ្រប់គ្រងពាណិជ្ជកម្ម | 0414 |
| ហិរញ្ញវត្ថុ និងធនាគារ | 0412 |
| សេដ្ឋកិច្ច និងគ្រប់គ្រង | 0311 |
| គ្រប់គ្រង និងរដ្ឋបាល | 0413 |
| និតិសាស្ត្រ | 0421 |
| បច្ចេកទេសអូឌីយ៉ូ-វីដេអូ និង ការផលិតប្រព័ន្ធផ្សព្វផ្សាយ | 0211 |
| សង្គមវិទ្យា និងការសិក្សាវប្បធម៌ | 0314 |
| ស្ថិតិ | 0542 |

**នាយកគ្រប់គ្រងការលក់ និងទីផ្សារ**
- 900-1200 $
- បទពិសោធន៍: 5 ឆ្នាំឡើងទៅ
- ជំនាញទំនាក់ទំនង
- ការត្រិះរិះពិចារណា
- ការគ្រប់គ្រងពេលវេលា

**នាយកគ្រប់គ្រងធនធានមនុស្ស**
- 800-1200 $
- បទពិសោធន៍: 5 ឆ្នាំឡើងទៅ
- ភាពជាអ្នកដឹកនាំ
- ការគិតបែបវិជ្ជមាន
- ការសម្របសម្រួល

**អ្នកជំនាញផ្នែកផ្សព្វផ្សាយ និងទីផ្សារ**
- 400-600 $
- បទពិសោធន៍: 3-5 ឆ្នាំ
- ជំនាញទំនាក់ទំនង
- ការគ្រប់គ្រងពេលវេលា
- ការនិយាយជាសាធារណៈ

## ជំនាញមធ្យម(កម្រិត២) — គុណវុឌ្ឍិ៖ មធ្យមសិក្សាទុតិយភូមិ ឬ សញ្ញាបត្របច្ចេកទេស & វិជ្ជាជីវៈ១ ២ និង៣ ឡើងទៅ

| មុខជំនាញ | ISCED-F 2013 |
|---|---|
| គណនេយ្យ និងពន្ធដារ | 0411 |
| ហិរញ្ញវត្ថុ និងធនាគារ | 0412 |
| ការគ្រប់គ្រង និងរដ្ឋបាល | 0413 |
| ភាសាបរទេស | 0231 |
| ច្បាប់ការងារ | 0421 |
| អេឡិចត្រូនិក | 0714 |
| សំណង់ និងវិស្វកម្មស៊ីវិល | 0732 |
| អគ្គិសនី | 0713 |
| កម្មវិធីកុំព្យូទ័រ | 0611 |
| មូលដ្ឋានទិន្នន័យ និងការ គ្រប់គ្រងបណ្តាញ | 0612 |
| សូហ្វវែរ និងការអភិវឌ្ឍកម្មវិធី | 0613 |

**បុគ្គលិកទូទៅផ្នែកកត់ត្រាគណនេយ្យ និងបញ្ជី**
- 300-400 $
- បទពិសោធន៍: 1-3 ឆ្នាំ
- ការដោះស្រាយបញ្ហា
- ការរៀបចំ និងផែនការ
- ភាពស្មោះត្រង់ និងសុចរិតភាព

**លេខាធិការ (ទូទៅ)**
- 400-500 $
- បទពិសោធន៍: 1-3 ឆ្នាំ
- ការសម្របសម្រួល
- ការគ្រប់គ្រងពេលវេលា
- ការនិយាយជាសាធារណៈ

**ជាងអគ្គិសនីទូទៅ**
- 350-450 $
- បទពិសោធន៍: 1-3 ឆ្នាំ
- ការគិតបែបវិភាគ
- ការធ្វើការងារជាក្រុម
- យល់ដឹងពីសុវត្ថិភាព និងការប្រុងប្រយ័ត្ន

**អ្នកតម្លើង និងអ្នកផ្តល់សេវាបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា**
- 350-450 $
- បទពិសោធន៍: 1-3 ឆ្នាំ
- ការដោះស្រាយបញ្ហា
- ជំនាញទំនាក់ទំនង
- ការធ្វើការងារជាក្រុម

**ជំនាញទាប (កម្រិត១)** — គុណវុឌ្ឍិ៖ មធ្យមសិក្សាបឋមភូមិ ឬ វិញ្ញាបនបត្រវិជ្ជាជីវៈឡើងទៅ

| មុខជំនាញ | ISCED-F 2013 |
|---|---|
| ជំនាញដែលមិនបានធ្វើចំណាត់ថ្នាក់ (ដាក់ និងរៀបអីវ៉ាន់តាមធ្នើរ) | 0419 |
| ជំនាញដែលមិនបានធ្វើចំណាត់ថ្នាក់ (ប្រើឧបករណ៍លើក និងជញ្ជូនទំនិញ) | 0799 |
| សំណង់ | 0732 |
| សុវត្ថិភាព និងសុខភាពការងារ | 1022 |
| ជំនាញដែលមិនបានធ្វើចំណាត់ថ្នាក់ (ការងាររៀបឥដ្ឋ) | 0719 |
| សេវាបំរើតាមផ្ទះ | 1011 |
| បដិសណ្ឋារកិច្ច | 1013 |

**អ្នករៀបដាក់ទំនិញតាមធ្នើរក្នុងឃ្លាំង**

- 210-250 $
- បទពិសោធន៍: 0-2 ឆ្នាំ
- ការគ្រប់គ្រងពេលវេលា
- ការធ្វើការងារជាក្រុម
- ភាពហ្មត់ចត់ និងការយកចិត្តទុកដាក់

**កម្មករផលិតកម្មដែលមិនបានធ្វើចំណាត់ថ្នាក់**

- 210-250 $
- បទពិសោធន៍: 0-2 ឆ្នាំ
- ជំនាញទំនាក់ទំនង
- ការធ្វើការងារជាក្រុម
- ការគ្រប់គ្រងពេលវេលា

**អ្នកជួយការងារកន្លែងចម្អិនអាហារ**

- 150-175 $
- បទពិសោធន៍: 0-2 ឆ្នាំ
- ការធ្វើការងារជាក្រុម
- ការគ្រប់គ្រងពេលវេលា
- ជំនាញទំនាក់ទំនង

ចំនួនការងារសរុប: 35,940 នាក់

ក្រុមហ៊ុនកំពុងប្រកាសជ្រើសរើស (%នៃក្រុមហ៊ុនសរុប): 21.43 %

ការប៉ាន់ស្មានចំនួនជ្រើសរើសបុគ្គលិក: 5,334 កន្លែង

ការលំបាកក្នុងការជ្រើសរើសបុគ្គលិក (%នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក): 3.10 %

ក្រុមហ៊ុនផ្តល់ឱកាសឲ្យអ្នកគ្មានបទពិសោធន៍ (%នៃក្រុមហ៊ុនសរុប): 11.46 %

ឱកាសការងារក្នុងអនុវិស័យនេះ: 2.18

កង្វះខាតជំនាញ (% នៃក្រុមហ៊ុនជ្រើសរើសបុគ្គលិក): 0.52 %

ក្រុមហ៊ុនដែលជួបបញ្ហាគម្លាតជំនាញ (%នៃក្រុមហ៊ុនសរុប): 10.41 %

រាជធានីខេត្តទាំង ៣ ដែលមានតម្រូវការការងារខ្ពស់



# អនុវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប

## ជំនាញខ្ពស់(កម្រិត៣ និង៤)

គុណវុឌ្ឍិ៖ បរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ

| មុខជំនាញ | ISCED-F 2013 | មុខរបរ | ប្រាក់ខែ | បទពិសោធន៍ | ជំនាញ |
|---|---|---|---|---|---|
| អក្សរសាស្ត្រ និង ភាសាវិទ្យា | 0232 | អ្នកបកប្រែអត្ថបទ អ្នកបកប្រែផ្ទាល់មាត់ និងភាសាវិទូដទៃទៀត | 500-600 $ | 3-5 ឆ្នាំ | • ជំនាញទំនាក់ទំនង<br>• ភាពអត់ធ្មត់<br>• ការគ្រប់គ្រងពេលវេលា |
| ទំនាក់ទំនងអន្តរជាតិ | 0312 | | | | |
| ភាសាបរទេស | 0231 | | | | |
| បច្ចេកទេសអូឌីយ៉ូ-វីដេអូ និងការផលិតប្រព័ន្ធផ្សព្វផ្សាយ | 0211 | អ្នកជំនាញផ្នែកផ្សព្វផ្សាយ និងទីផ្សារ | 500-550 $ | 3-5 ឆ្នាំ | • ជំនាញទំនាក់ទំនង<br>• ការគ្រប់គ្រងពេលវេលា<br>• ការនិយាយជាសាធារណៈ |
| សង្គមវិទ្យា និងការសិក្សាវប្បធម៌ | 0314 | | | | |
| ស្ថិតិ | 0542 | | | | |
| វាយនភណ្ឌ | 0723 | អ្នករចនាម៉ូតផលិតផល និងសម្លៀកបំពាក់ | 450-500 $ | 3-5 ឆ្នាំ | • ភាពច្នៃប្រឌិត និងនវានុវត្តន៍<br>• ការងារក្រុម<br>• ការគ្រប់គ្រងពេលវេលា |
| រចនាក្រាហ្វិច | 0211 | | | | |
| ការរចនាម៉ូដសម្លៀកបំពាក់ និងផលិតផលឧស្សាហកម្ម | 0212 | | | | |

## ជំនាញមធ្យម(កម្រិត២)

គុណវុឌ្ឍិ៖ មធ្យមសិក្សាទុតិយភូមិ ឬ សញ្ញាបត្របច្ចេកទេស & វិជ្ជាជីវៈ១ ២ និង៣ ឡើងទៅ

| មុខជំនាញ | ISCED-F 2013 | មុខរបរ | ប្រាក់ខែ | បទពិសោធន៍ | ជំនាញ |
|---|---|---|---|---|---|
| អគ្គិសនី | 0713 | ជាងអគ្គិសនីទូទៅ | 350-400 $ | 1-3 ឆ្នាំ | • ភាពហ្មត់ចត់ក្នុងការងារ<br>• ការដោះស្រាយបញ្ហា<br>• ការគ្រប់គ្រងពេលវេលា |
| អេឡិចត្រូនិក | 0714 | | | | |
| សំណង់ និងវិស្វកម្មស៊ីវិល | 0732 | | | | |
